# សហឧក្រិដ្ឋកម្មរួម (Joint Criminal Enterprise: JCE)

ទម្រង់នៃការទទួលខុសត្រូវនេះ លេចជារូបរាងច្បាស់ក្នុងយុត្តិសាស្ត្រ *Tadic* (IT-94-1-A, 1999, paras.185-192) ដែលដាក់នាំឲ្យការទទួលខុសត្រូវ ផ្អែកតាមផែនការរួម (common purpose) ទោះបី លក្ខន្តិកៈនៃ ICTY មិនបានចែងច្បាស់អំពីទម្រង់នេះក្តី។

នេះមកពីមូលហេតុថា លក្ខន្តិកៈ ចង់ពង្រីកវិសាលភាពដល់បុគ្គលទាំងអស់ ដែលបំពានច្បាប់មនុស្សធម៌អន្តរជាតិ (international humanitarian law) ។ បទឧក្រិដ្ឋអន្តរជាតិ (international crimes) ត្រូវបានប្រព្រឹត្ត ដោយបុគ្គលជាច្រើន ដើម្បីសម្រេចនូវគោលបំណងរួម។ ក្នុងន័យនេះ ទម្រង់នេះ អនុញ្ញាតឲ្យមានការកាត់ទោស បុគ្គលក្នុងនាមជាសហការី (co-perpetrator) ទោះបីមិនបានប្រព្រឹត្តផ្ទាល់ក្តី។

JCE មានបីប្រភេទ៖ ទី១. ចម្បង (basic) ទី២. ទម្រង់ប្រព័ន្ធប្រព្រឹត្តមិនគម្បី (ill-treatment system) និងទី៣. ទម្រង់លាតសន្ធឹង (extended) ។ ទម្រង់ទាំងបីនេះ មានធាតុផ្សំរួម៖ ១. មានមនុស្សចាប់ពីពីរនាក់ឡើងទៅចូលរួម ដោយមិនចាំបាច់មានរចនាសម្ព័ន្ធរដ្ឋបាលអ្វីទេ។ ២. មានផែនការរួម ដែលមិនចាំបាច់មានជាមុន ឲ្យតែជា ឬជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស និងទី៣. ចូលរួមក្នុងគម្រោង ដោយប្រព្រឹត្តនូវបទល្មើសណាមួយ។

ធាតុផ្សំសំភារៈ ក៏រាប់ចូលនូវការខកខាន (omission) ដែរ។ ជាចុងក្រោយ ចំណងហេតុនិងផល (causation) ក៏មិនទាមទារផងដែរ។ ការចូលរួមក្នុងផែនការរួម ដូចជាការប្រព្រឹត្តសកម្មភាពល្មើសណាមួយ មិនចាំបាច់ដល់កម្រិតថា មិនមានការចូលរួម បទល្មើសនឹងមិនកើតមានឡើងនោះឡើយ។ យុត្តិសាស្ត្រ ទាមទារថាការចូលរួមមានកម្រិត significant ជួយដល់បទល្មើស។

ធាតុផ្សំអត្តនោម័តសម្រាប់ប្រភេទទី១ គឺសមាជិកក្នុងក្រុមទាំងអស់ ត្រូវតែមានចេតនាដូចគ្នា (intent) ក្នុងការប្រព្រឹត្ត។ សម្រាប់ប្រភេទទី២ ជនល្មើស បានដឹងពីប្រព័ន្ធប្រព្រឹត្តមិនគម្បី និងមានចេតនាក្នុងការជម្រុញនូវប្រព័ន្ធ។ ប្រភេទទី៣ ជនល្មើស បានដឹងថាបទល្មើសក្រៅផែនការរួម អាចនឹងត្រូវបានប្រព្រឹត្ត (foreseeable) ហើយគាត់នៅមានចេតនាចូលរួមប្រព្រឹត្ត។

យុត្តិសាស្ត្រមិន តម្រូវឲ្យមានបញ្ជីជាក់ស្តែងនៃសមាជិក JCE ហើយ អ្នកប្រព្រឹត្ត ក៏មិនចាំបាច់ត្រូវតែជាសមាជិកដែរ ដើម្បីទាំឲ្យមានការទទួលខុសត្រូវ ឲ្យតែទង្វើនោះជាប់ពាក់ព័ន្ធនឹងសមាជិកណាម្នាក់ (attribution)។ អ្នកស្រាវជ្រាវ បានរិះគន់ទម្រង់ JCE ដោយសារ វាទំនងជាដាក់ការទទួលខុសត្រូវលើ

ជនណាម្នាក់ ដោយសារគាត់គ្រាន់តែចូលរួមក្នុងក្រុម (guilty by association) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 391-396)។

**ខ្លឹមសារបន្ថែម៖** ផែនការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ដោយមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ជាផែនការរួម។ មេដឹកនាំ ដែលចូលរួមសម្រេចដាក់ផែនការនេះ (ទម្រង់ទី១)។ ទាហានម្នាក់បានដឹងពីផែនការជម្លៀស និងដឹងថា ក្នុងអំឡុងពេលជម្លៀស នឹងមានការតវ៉ា ហើយទាហានជាមិត្តអាចបាញ់ប្រជាជន (បទល្មើសក្រៅផែនការរួម) ទាហានទី១ នឹងទទួលខុសត្រូវតាម JCE ទម្រង់ទី៣។ ***អវតក*** បានពិភាក្សាយ៉ាងផុសផុល អំពីថាតើ JCE ទាំងបីទម្រង់ ជាវិធានទំនៀមទម្លាប់អន្តរជាតិ។ ***អវតក*** បានអះអាងថា ទម្រង់ទីបី មិនមែនជាវិធានបែបនេះនៅមុនឆ្នាំ ១៩៧៥ទេ (D97/15/9, 2010, para.77) ដូចនេះ ការដាក់ឲ្យមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទទួលខុសត្រូវតាមទម្រង់នេះ គឺផ្ទុយនឹងគោលការណ៍នីត្យានុកូលភាព (principle of legality)។